

មានសេចក្តីជំនឿលើសេចក្តីល្អរបស់ព្រះ



(19)

នេះគឺជាពាក្យរបស់លោក ដេវក ព្រីនស៍
ដែលបានដកស្រង់ពីព្រះបន្ទូលនៃព្រះសម្រាប់លោកអ្នក។

> តែបើឥតមានសេចក្តីជំនឿទេ
> នោះមិនអាចនឹងគាប់ដល់ព្រះហឫទ័យព្រះបានឡើយ
> ត្បិតអ្នកណាដែលចូលទៅឯព្រះ នោះត្រូវតែជឿថា
> មានព្រះមែន
> ហើយថាព្រះអង្គប្រទានរង្វាន់ដល់អស់អ្នកដែលស្វែងរក
> ព្រះអង្គ។ [ហេព្រើរ ១១:៦]

ប្រសិនបើខ្ញុំចង់សួរអ្នកថា តើអ្វីដែលសំខាន់បំផុត -
តើអ្វីទៅដែលសំខាន់
ប្រសិនបើអ្នកចង់ដឹកនាំជីវិតដែលគាប់ដល់ព្រះហឫទ័យព្រះ?
ខ្ញុំចង់ដឹងពីរបៀបដែលអ្នកនឹងឆ្លើយ។ ប្រហែលជាអ្នកអាចនិយាយថា
ធ្វើជាអ្នកកាន់សាសនា ទៅព្រះវិហារឲ្យបានទៀងទាត់
ផ្តល់ប្រាក់ឧបត្ថម្ភទៅឱ្យអង្គការសប្បុរសធម៌
គោរពតាមក្រឹត្យវិន័យទាំង ១០ ប្រការ
ជៀសឲ្យផុតពីការប្រព្រឹត្តអំពើបាប ពីអំពើអសីលធម៌ ពីការស្រវឹង
និងជៀសពីការផ្សេងៗដែលស្រដៀងនឹងការទាំងអស់នេះ។
រឿងទាំងអស់នេះអាចល្អ ប៉ុន្តែក្នុងចំណោមពួកវា
គ្មានការណាមួយដែលសំខាន់ដូចជាការគាប់ដល់ព្រះហឫទ័យព្រះ
នោះទេ។ ការមួយដែលព្រះទ្រង់តម្រូវនៅក្នុងយើងទាំងអស់គ្នា
គឺជាការមួយ បើគ្មានវាទេ
យើងមិនអាចគាប់ដល់ព្រះហឫទ័យព្រះបានឡើយ
នោះគឺជាសេចក្តីជំនឿ
ហើយជំនឿនោះត្រូវបានសម្តែងចេញតាមវិធីពីរយ៉ាង។

ទីមួយយើងត្រូវជឿថាមានព្រះ។ ភាគច្រើនយើងគិតថា
នៅក្នុងដួងចិត្តរបស់យើងពិតជាដឹងអំពីរឿងនេះ
ប៉ុន្តែលើសពីនេះទៅទៀត
យើងត្រូវតែជឿថាព្រះប្រទានរង្វាន់ដល់អស់អ្នកដែលស្វែងរកទ្រង់យ៉ា
ងអស់ពីចិត្ត។ អ្នកឃើញទេ សេចក្តីជំនឿ គឺជាអ្វីៗទាំងអស់
មានជំនឿលើសេចក្តីល្អរបស់ព្រះ ជឿទុកចិត្តលើទ្រង់
ពឹងផ្អែកទៅលើទ្រង់
ហើយបើគ្មានសេចក្តីជំនឿលើសេចក្តីល្អរបស់ព្រះទេ
នោះយើងមិនអាចគាប់ព្រះហឫទ័យដល់ព្រះបានទេ។
វាចាប់ផ្តើមដោយការជឿលើព្រះ និងសេចក្តីល្អរបស់ទ្រង់។
នេះគឺជាឫសគល់
និងជាប្រភពនៃភាពជោគជ័យដ៏ពិតប្រាកដទាំងអស់

© 1970 — Derek Prince Ministries - International®

និងជីវិតដែលគាប់ព្រះហឫទ័យដល់ព្រះ។

: WD-WFTW-019-KHM
: 24 Feb 2026
: derekprince.com/km/resources

